# ការសម្ភាសរបស់ អ្នកមីង ពិន ស្រី

ក៖ អ្នកធ្វើការសំភាសន៍ឈ្មោះ ហេង សុជីវី ខ៖ អ្នកត្រូវគេសំភាសន៍ឈ្មោះ ពិន ស្រី

ក៖ ចាសជំរាបសួរអ៊ី

ខ៖ ចាស

ក៖ ចាស អ៊ីមានឈ្មោះអ្វីដែរ?

ខ៖ ខ្ញុំឈ្មោះស្រី

ក៖ អ៊ីឈ្មោះពេញឈ្មោះអ្វីដែលត្រូវជាមួយអត្តសញ្ញាណប័ត្រ?

ខ៖ ឈ្មោះស្រីនឹង

ក៖ ឈ្មោះក្នុងអត្តសញ្ញាណប័ត្រឈ្មោះអ្វីដែរ?

ខ៖ ឈ្មោះស្រីនឹងឈ្មោះពិន ស្រី

ក៖ ឈ្មោះពិន ស្រី អ៊ីខ្ញុំហៅអ្នកមីងបានអត់?

ខ៖ បាន

ក៖ ចាសអ្នកមីងពិនស្រីអ្នកមីងមានអាយុប៉ុន្មានហើយឆ្នាំនឹង?

ខ៖ ខ្ញុំមានអាយុ៥២ហើយ។

ក៖ ចាសអាយុ៥២ហើយកើតនៅឆ្នាំណាដែលអ្នកមីង?

ខ៖ ដឹងថាឆ្នាំណាព្រោះថាកំព្រាម៉ែឪតាំងពីតូចមកដឹងថាកើតមមី ខែ១ ថ្ងៃ១ តែមិនដឹងថាឆ្នាំ២០០០មានទេ។

ក៖ ចាស ហើយអ្នកមីងមានទីលំនៅនៅភូមិឃុំខេត្តណាដែរ?

ខ៖ ស្រុកកំណើតអេស?

កៈ ចាស

ខៈ ស្រុកកំណើតនៅភូមិព្រៃពួត អង្គួល ស្គាល់ទេ?

កៈ ចាស

ខៈ ហើយនៅឃុំព្រៃពួត ភូមិទូលលាប ស្រុកព្រៃពួន។

កៈ ខេត្ត?

ខៈ ខេត្តកណ្តាល

កៈ ចាសចឹងទីលំនៅនៅខេត្តនេះផ្ទាល់តែម្តង?

ខៈ ចាស

កៈ ហើយអ្នកមីងមានលោកយាយលោកតាត្រូវជាឪពុកម្តាយរបស់អ្នកមីងនៅរស់ទេសព្វថ្ងៃ?

ខៈ ស្លាប់អស់ហើយ។

កៈ តើគាត់ស្លាប់នៅជំនាន់អាពតឬក៏ស្លាប់ដោយសារជំងឺ?

ខៈ ចាសក៏ស្លាប់នៅជំនាន់អាពតប៉ុន្តែម៉ាក់គាត់បានបែកគ្នាតាំងពីខ្ញុំនៅតូចៗមក។

កៈ ចាសចុះអ្នកមីងមានស្គាល់ឈ្មោះគាត់អត់?

ខៈ ស្គាល់

កៈ គាត់ឈ្មោះអ្វីដែលទាំងពីរនាក់?

ខៈ ម៉ាក់វ៉ាន់ ណា ប៉ាឈ្មោះប៉ុន

កៈ ចាសគាត់ស្លាប់នៅអាយុឬព្រះជនប៉ុន្មានដែរ?

ខៈ អត់ដឹងថានៅអាយុប៉ុន្មានដែរព្រោះអីគាត់លែងគ្នាតាំងពីខ្ញុំនៅតូចៗ។

កៈ អូ យូហើយហើយអ្នកមីងមានបងប្អូនប៉ុន្មាននាក់?

ខ៖ មាន២នាក់

ក៖ ២នាក់ ហើយមីងកូនទីប៉ុន្មានដែរ?

ខ៖ ខ្ញុំកូនបងគេ។

ក៖ កូនបងគេម៉ង ហើយមួយទៀតកូនប្អូន។

ខ៖ មួយទៀតកូនប្អូន។

ក៖ កូនប្រុសឬកូនស្រី?

ខ៖ កូនប្រុស

ក៖ ចុះគាត់មានគ្រួសារនៅប្អូនអី?

ខ៖ មានហើយ

ក៖ គាត់មានឈ្មោះអ្វីដែលប្អូនអី?

ខ៖ ឈ្មោះប៊ុន ធឿន

ក៖ ចាស គ្រួសារគាត់នៅម្តុំនេះដែលឬគាត់ទៅនៅទីណា?

ខ៖ អត់ទេគាត់នៅជិតផ្សារខ្មេរទទឹងជិតភ្នំស្រង់។

ក៖ ចាស គាត់ដែលមកលេងអីហើយអីមានដែលទៅលេងគាត់ទេ?

ខ៖ អត់ដែលមកទេ តែខ្ញុំទៅ។

ក៖ ចាស ចូលឆ្នាំអីនឹងក៏ទៅលេងគ្នាទៅ?

ខ៖ ចាស

ក៖ ចាស បងប្អូន២នាក់ហើយមីងឥឡូវមានគ្រួសារហើយឬនៅ?

ខ៖ ខ្ញុំប្តីលែងគ្នាបែកគ្នាអស់ហើយ។

កះ ហឺស ចុះមានកូនអត់អី?

ខះ មានកូនអាយុ១០។

កះ កូនតែមួយនាក់ទេ១០ឆ្នាំ

ខះ កូនប្រុសគាត់មានរៀនទេ?

កះ រៀន

ខះ រៀនថ្នាក់ទីប៉ុន្មានដែរ?

កះ ទី២

ខះ ត្រឹម ថ្នាក់ទី២កូនប្រុសរៀនថ្នាក់ទី២ ចាសហើយគាត់សព្វថ្ងៃនឹងនៅជាមួយអី?

កះ ចាស ហើយផ្ទះអីនៅជិតនេះទេ?

ខះ នៅជិតនឹង

កះ ហើយសព្វថ្ងៃប្រកបមុខរបរអ្វីដែលអី?

ខះ ប៉ះត្រកួនប៉ះអីអោយគេនឹង។

កះ ប៉ះត្រកួនតែមួយមុខនឹងទេហ៎អី?

ខះ នឹងហើយ

កះ មួយថ្ងៃបានចំណូលប៉ុន្មានដែរ?

ខះ
បានយើងប៉ះបានច្រើនបានលុយច្រើនហើយបើយើងប៉ះបានតិចបានលុយតិចចឹងទៅណា។

កះ ចាស យើងប៉ះបានច្រើនក្នុងមួយថ្ងៃតើប្រហែលជាមួយថ្ងៃបានប៉ុន្មាន?

ខះ បើយើងប៉ះបាន១០០ដុំ ១ដុំ៣០០រ បានតែ៣០០០០រ ទេ បើ១ដុំ ៤០០រ បាន៤០០០០រ។

កៈ ចាសបានច្រើនដែលតើ អឺមហាហា

ខៈ ច្រើនហាហា

កៈ
អាចចិញ្ចឹមកូនបានហើយអ៊ីហើយអ៊ីគិតថាចំណូលបែបនឹងអាចចិញ្ចឹមគ្រួសារបានដែលឬទេឬក៏អ៊ីចង់បានប៉ុន្មានដែលគ្រប់គ្រាន់?

ខៈ នឹងយើងនៅតែខ្វះខាតចឹងថ្ងៃណាខ្លះទៅយើងនៅផ្ទះទៅ។

កៈ ចឹងត្រកួននឹងប៉ះពីចំការគេនេសអ៊ីនេស?

ខៈ នឹងហើយទៅអុំទៅអុំទូកនៅបឹង។

កៈ ចាសហើយនៅឆ្ងាយពីនេះទេអ៊ី?

ខៈ នោះមើលពីនេះទៅឃើញ។

កៈ បានច្រើនដែលយើងប៉េះរាល់ថ្ងៃតែម្ដង?

ខៈ យើងប៉េះបានរាល់ថ្ងៃដែលយើងទៅប៉េះចឹងថ្ងៃណាគេអត់មានអីអោយយើងប៉េះដែលនឹង?

កៈ យើងជួលគេ?

ខៈ អត់ទេណានឹងយើងសុំគេ។យើងអត់ដាំ។

កៈ ចុះមួយថ្ងៃយើងដឹងតែបានប៉ុណ្ណឹងតែម្ដង?

ខៈ នឹងហើយដឹងតែមួយដុំ៤០០របាន៤០០០០ ១០បានមួយដុំ៣០០រ បានតែ៣០០០០រទេ។

កៈ យើងប៉េះបានច្រើនដែលនឹងទំរាំបាន៣០០០០រចឹង។

ខៈ ហឺស ប៉េះទំរាំបានទាល់តែម៉ោង៣ទៅម៉ោង៤នោះ បានមកផ្ទះ។

កៈ ចឹងអ៊ីចេញពីផ្ទះទៅម៉ោងប៉ុន្មានដែល?

ខៈ ទៅម៉ោង៦ប៉េះ

កៈ ចាសដល់ពេលចប់អាចម៉ោង៣

ខៈ ចាស

កៈ ចុះម៉ោងបាយវិញយ៉ាងម៉េចទៅ?

ខៈ បាយពេលព្រឹកហើយពេលថ្ងៃអត់ហូបទេ ហូបតែម្ដងនឹងដល់ល្ងាច។

កៈ អូ អ៊ីចឹងដល់ពេលនឹងអ៊ីមិនឃ្លានហើយចឹង?

ខៈ អត់អីទេទំលាបហើយ។

កៈ ទំលាបហើយចឹងសព្វថ្ងៃនឹងពិសាបាយតែពេលព្រឹកនឹងពេលល្ងាចទេ?

ខៈ ចាស

កៈ ចុះបាយម្ហូបនឹងអ៊ីធ្វើខ្លួនឯងឬទិញគេ?

ខៈ ធ្វើខ្លួនឯង

កៈ ធ្វើនៅផ្ទះខ្លួនឯង?

ខៈ ចាស

កៈ ចឹងដល់ពេលប៉េះគ្រកួនអីនឹងប៉េះបានមកហើយទិញសាច់អីតិចតួចចឹងទៅ?

ខៈ នឹងហើយ

កៈ ផ្សារនៅទីណាដែល?

ខៈ ផ្សារនៅផ្សារទឹកខ្មៅបើមិនចឹងទេទិញនៅផ្ទះគេនេះទៅ។

កៈ ចាសចឹងនៅជិតឥវ៉ាន់ចាបហួយតាមផ្ទះ ហើយអ៊ីចឹងផ្សារនឹងឆ្ងាយទេជិះប៉ុន្មាននាទីប៉ុន្មានគីឡូ?

ខៈ នៅផ្សារទឹកខ្មៅនឹង។

កៈ អ៊ីវាល់ដងអ៊ីចំនាយពេលទៅជិះកង់ឬជិះម៉ូតូ?

ខៈ ជិះកង់

កៈ ជិះកង់អ៊ីហ៎?

ខៈ ចាស

កៈ ប៉ុន្មាននាទីបានជិះដល់?

ខៈ អត់ដឹងទេប៉ុន្មាននាទីបានជិះដល់។

កៈ ចឹងមានន័យថាជៀក
ឧទាហរណ៍ពេលថ្ងៃអ៊ីចេញទៅប៉េះត្រកួនអ៊ីហើយចឹងអ៊ីមិនត្រូវសំរាកអ៊ីតិច
ហើយត្រូវទៅផ្សារដាំបាយអ៊ីអោយកូនញ៉ាំ។

ខៈ ចាស

កៈ ចឹងពេលថ្ងៃអ៊ីអត់បានញ៉ាំចឹងតើកូនបានអីញ៉ាំ?

ខៈ ដាំទុកពេលព្រឹកចឹងទុកអោយព្រោះយើងទៅនោះហើយ។

កៈ ហឺស ចឹងគាត់ទឹមតែរៀនថ្នាក់ទី២ចឹងគាត់ចេះធ្វើខ្លួនឯងហើយអ៊ី។

ខៈ អឺ កូននឹងវារៀនអត់សូវពូកែដែលទេកូននឹងហឺស។

កៈ អ៊ីដែលតាមដានការសិក្សារបស់គាត់ទេ?

ខៈ តាម

កៈ គាត់រៀនបានលេខប៉ុន្មាន?

ខៈ កាលខែមុនវារៀនបានលេខ១៤
តែខែនេះអត់ទាក់ដឹងព្រោះអត់បានមើលសៀវភៅតាមដានវាទៀតព្រោះគ្រូមិនទាន់ចែកអោយ។

កៈ ចាស អូរលេខ១៤ក្នុងចំណោមសិស្សប៉ុន្មាននាក់។

ខៈ ប្រហែលសិស្ស៥០នាក់។

កៈ ហូស ៥០នាក់ហ៎ា ចឹងបានពូកែដែលតើ៥០នាក់បានលេខ១៤។
ចុះអ៊ីដូចថាកូនរៀនរាងគ្រាន់បើដែលចឹងគាត់ត្រឹមតែអាយុ២ឆ្នាំនឹងចឹងរាល់ថ្ងៃគាត់
ពេលដែលអ៊ីមកធ្វើការឬមកប៉េះត្រកួនអីនឹងគាត់រៀបចំផ្ទះដោយខ្លួនឯងទៅន៎?

ខៈ ហឺ

កៈ តើគាត់ចេះធ្វើអ្វីខ្លះទៅ?

ខៈ គាត់ដល់ពេលខ្ញុំទៅផ្សារអីចឹងគាត់បានដើរកាត់ពោតអោយគេទៅគេអោយបាន១០០០០រ
ទុកហូប។

កៈ អូ ពូកែមែនទែនត្រឹមតែក្មេងសោះចេះរកលុយ សូមសរសើរកូនអ៊ី
តើអ៊ីរាល់ថ្ងៃបានប្រាប់គាត់ថាយ៉ាងម៉េចខ្លះអ៊ី?

ខៈ ប្រាប់ថាកូនឯងម៉ែអត់លុយទេ ចឹងវាក៏ដើរទៅកាត់ពោតនឹងស៊ីជួលប៉េះពោតអោយគេ។

កៈ ចាសអ៊ីជីវិតចឹងហើយ អ៊ី
ហើយអ៊ីតាំងពីនេះមកនៅស្រុកកំណើតនៅនេះតែម្តងឬនៅឯណាដែលអ៊ី?

ខៈ ប្តូរពីព្រៃកពួតនឹងមកនេះវិញ មកនៅនេះមកជួលដីគេនៅក្រោយហ៎ា។

កៈ ជួលគេទៀតដីនឹង?

ខៈ ចាស ក្នុងមួយខែ១៥០០០រ។

កៈ ហើយផ្ទះអ៊ីមានធ្វើខ្លួនឯងឬជួលគេ?

ខៈ ធ្វើខ្លួនឯងហើយជួលដីគេតែ១៥០០០រទេ។

កៈ ចាស

ខៈ បើយើងជួលគេតែនេះម្តង៤០០០០រ។

កៈ ហឺ ចឹងជួលគេមួយខែ៤០០០០រចឹងជួលគេជួលអី ហើយផ្ទះនេះទំហំប៉ុន្មានដែរ?

ខៈ ៥ ខ្ញុំធ្វើតូចដែល

កៈ នៅជិតនឹងហ៎អឺ?

ខៈ ចាសនៅជិតនឹងតើ នៅក្រោយនោះឃើញតង់។

កៈ ចាសៗ ហើយអឺទិញសំភារគេដែល?

ខៈ ចាស ហើយជួលអោយគេធ្វើអោយដែល។

កៈ អស់ប៉ុន្មានដែលអឺ?

ខៈ តឹងធ្វើអស់៦០ម៉ឺន ទិញឈើ ទិញអីនឹងទិញប៉ាងឬស្សីអីទៀត។

កៈ ចាស ចាំមើលពេលចប់សំភាសន៍ខ្ញុំចង់សុំការអនុញ្ញាតពីអឺទៅមើលមួយភ្លែកបានអត់?

ខៈ បាន

កៈ ហើយអឺផ្ទះនេះមានអាយុកាលប៉ុន្មានឆ្នាំហើយ?

ខៈ ខ្ញុំមកនៅនេះតាំងពីកូនខ្ញុំនេះ តាំងប្រហែលជា១០ឆ្នាំហើយតាំងពីខ្ញុំនៅនេះ។

កៈ ចាស អឺហើយអឺអឺ ដូចថាអឺបានលែងលះជាមួយស្វាមីបានប៉ុន្មានឆ្នាំដែល?

ខៈ លែងលះបាន២ឆ្នាំ

កៈ ២ឆ្នាំហើយ ហើយគាត់ដែលមកអើតអីដែស?

ខៈ អត់ផង

កៈ អត់មកមើលកូនអីទេ?

ខៈ អត់ទេ

កៈ តែមួយដងក៏អត់ដែល?

ខ៖ គាត់គ្មានមកជួយមើលយើងទេ។

ក៖ ចុះអ៊ីមានដែលទាក់ទងទៅគាត់ទេ?

ខ៖ អត់

ក៖ ចឹងអ៊ីមាននឹងគាត់អត់ចឹង?

ខ៖ អត់ទេ អត់មាននឹងអត់មានអីផង។ដូចដាច់អាល័យអត់មាននេះផង។

ក៖ គាត់ភ្លាប់ធ្វើបាបអ៊ីអត់អ៊ី?

ខ៖ ចាស

ក៖ គាត់ធ្វើអ្វីខ្លះអ៊ី?

ខ៖ គាត់វ៉ៃ គាត់អីចឹង។

ក៖ អូ គាត់ប្រើអំពើហិង្សាលើអ៊ីហ៎ ?

ខ៖ ចាស

ក៖ គាត់ធ្លាប់មានធ្វើអោយអ៊ីរបួសស្នាក់ស្នាមទេអ៊ី?

ខ៖ អត់ទេ គាត់អត់មានវ៉ៃអោយរបួសស្នាកស្នាមទេ។

ក៖ ចុះអ៊ីមានធ្លាប់ប្រាប់អ្នកជិតខាងនិងអាជ្ញាធរពីបញ្ហានឹងទេ?

ខ៖ ប្រាប់

ក៖ គាតជួយអន្តរាគមន៍លើគ្រួសារអ៊ីទេ?

ខ៖ គេជួយតើ។

ក៖ ចាស ធ្លាប់មានអ្នកជួលឧបបមអ៊ីដែលទេ?

ខ៖ អត់ផងអត់ដែលមានផង។

កៈ ហើយដល់ពេលគាត់ជួយនឹងតើគាត់ជួយអ្វីគេខ្លះទៅ?

ខៈ គាត់គ្រាន់តែជួយប្រាប់កុំអោយវ៉ៃធ្វើបាបខ្ញុំចឹង។

កៈ ហេតុអ្វីបានជាគាត់វ៉ៃធ្វើបាបអីចឹង គាត់ផឹកស្រាមែន?

ខៈ ចាសពេលគាត់ស្រវឹង។

កៈ គាត់ធ្វើការអ្វីដែលអ៊ីប្ដីអី?

ខៈ គាត់ធ្វើសន្តិសុខ។

កៈ នៅឯណា?

ខៈ គាត់ធ្វើសន្តិសុខនៅសហ្គាតាកសិករតែឥឡូវគាត់ដូរហើយ
គាត់ធ្វើនៅឯណាទៀតខ្ញុំអត់ដឹងដែរ?

កៈ ចាស ទាល់តែនេះមកបានជាគាត់ឈប់មកផ្ទះ?

ខៈ ចាស

កៈ ចឹងឥឡូវអីមានដឹងថាគាត់មានប្រពន្ធមួយទៀតឬក៏អីអី?

ខៈ ខ្ញុំអត់ដឹងដែលព្រោះខ្ញុំអត់បានស៊ើប គាត់ពីអានឹងផង
ព្រោះថាដល់តែពីបែកគ្នាមកគាត់ទៅណាជារឿនរបស់គាត់ហើយខ្ញុំទៅណាក៏ជារឿងរបស់ខ្ញុំ។

កៈ ចាស យើងដាច់គ្នាហើយហើយ។យើងរស់នៅផ្សេងគ្នា
ចុះអីឥឡូវលែងនឹងគាត់ហើយស្រលាញ់គាត់ទៀតហើយ?

កៈ អត់

ខៈ ហាហា ដាច់ចិត្តរាងខ្លួន។

កៈ ចុះកាល
មុននឹងអីរៀបការដោយឪពុកម្ដាយជាអ្នកដាក់ទុកអោយឬរៀបការដោយស្រលាញ់គ្នា?

ខ៖ យើងរៀបនឹងដូចថាខ្លួនឯងទីពឹងខ្លួនឯងព្រោះខ្ញុំអត់មានឪពុកម្តាយផងព្រោះខ្ញុំមានអ៊ុំគាត់ចិញ្ចឹមតាំងពីនេះនឹងមកនៅជាមួយគាត់រហូត
តាំងបែកពពតមកខ្ញុំនៅជាមួយអ៊ុំខ្ញុំរហូតមក។

ក៖ ហឹស
ចឹងមានន័យថាអ៊ីស្រលាញ់គ្នាយកគ្នានឹងដោយចិត្តនឹងចិត្តទេមិនមែនបងប្អូនឬឪពុកម្តាយជាអ្នករៀបចំអោយទេ?

ខ៖ ចាស បើខ្ញុំនឹងអត់មានឪពុកម្តាយផង មានតែអ៊ុំ។

ក៖ អ៊ុំនឹងគាត់នៅណាដែលអ៊ី?

ខ៖ អ៊ុំខ្ញុំគាត់នៅភ្នំពេញ
ដល់ហើយខ្ញុំទៅបែកហើយបានជាខ្ញុំនៅជាមួយគាត់តាំងពីខ្ញុំនៅអាយុតូចៗមែស។

ក៖ ចុះអ៊ុំនឹងគាត់នៅឯណា?

ខ៖ ចាស គាត់នៅភ្នំពេញនឹង។

ក៖ គាត់មានស្រុកកំណើតនៅឯណា? ផ្ទះគាត់នៅភ្នំពេញតែម្តង?

ខ៖ ស្រុកកំណើតគាត់នៅឯអង្គួល បៀងបែកចាននេះដែល។

ក៖ គាត់ឈ្មោះអ្វីដែល?

ខ៖ គាត់ឈ្មោះអ៊ុំរិន

ក៖ អ៊ុំរិន ចុះអ៊ីឥឡូវនឹងអ៊ីមានបានចុះទៅលេងនឹងគាត់ទេ?

ខ៖ ខ្ញុំទៅ បើយូរចឹងខ្ញុំទៅបើនេះចឹងខ្ញុំអត់ដែលសូវទៅដែលនឹងយូរៗខ្ញុំទៅមួយដង។

ក៖ ចាស ទៅលេងគាត់ ហើយអ៊ី តាំងពីនេះមកអ៊ីក៏ធ្លាប់បានឆ្លងកាត់ជំនាន់អាពតដែល?

ខ៖ ចាស

ក៖ កាលនឹងអ៊ីអាយុប៉ុន្មានកាលនឹង?

ខ៖ ខ្ញុំជំនាន់ប៉ុលពតនឹងខ្ញុំមានអាយុ១៤ទៅ១៥ឆ្នាំនឹង។

ក៖ គេអោយអ៊ីធ្វើអ្វីខ្លះ?

ខ៖ ខ្ញុំនៅកងកុមារស្រួច លើប្រលាយអីវិញ លើកអាចម៍គោ លើប្រលាយ។

ក៖ ហ៊ី គេជំលាសអ៊ីពីណាទៅណា?

ខ៖ គេជំលាស់ ខ្ញុំនៅចេញពីព្រៃកពួតទៅ ទៅនៅ
ខ្ញុំនៅកងកុមារចឹងខ្ញុំដើរតែនៅចឹងទេផ្លាស់ទៅនៅកន្លែងបែកចានចឹងទេផ្លាស់ទៅនៅវត្តរកា
កោះអីចឹងចេះតែដើរទៅ ដើររហូតនឹងពួកខ្ញុំ ផ្លាស់ម្តងទៅនេះម្តងទៅនោះចឹងហាំ
យាមកងកុមារ។

ក៖ អ៊ីមានថាគេផ្លាស់កន្លែងអោយអ៊ីប៉ុន្មានដង?

ខ៖ ហួស ច្រើនកន្លែងណាស់។

ក៖ អ៊ីផ្លាស់ទៅណាខ្លះ?

ខ៖ ផ្លាស់ឧបមាថាយើងធ្វើកន្លែងមួយហើយចឹង
ផ្លាស់កន្លែងបែកចានចឹងហើយគេផ្លាស់ទៅនៅវត្តអាកាកោះ
ពេលធ្វើនឹងហើយទៀតយើងចេះតែដើរទៅទៀតហើយទៅវត្តអង្គតាព្រួចចេះតែដើរទៅតាមគេ
ពេលនឹង។

ក៖ ចឹងគ្រួសារអីគេជំលាសទៅជាមួយអត់?

ខ៖ ខ្ញុំអី ម៉ែខ្ញុំគេនឹងប៉ាខ្ញុំនឹងគាត់នៅជាមួយគ្នាតាំងពីខ្ញុំនៅតូចៗព្រោះប៉ាម៉ាក់ លែងគ្នា
ខ្ញុំនៅចឹងដល់ពេលហើយយាយនៅ
ហើយយាយស្លាប់ចឹងក៏នៅជាមួយមីងប៉ុន្តែមីងនៅកងស្រួចដែលហើយខ្ញុំនៅកងកុមារដែលប៉ុ
ន្តែអត់មានកងណានៅផ្ទះផង គិតទៅដល់ថ្ងៃ១០បានគេអោយយើងបានជួបគ្នាមួយដង
ថាថ្ងៃ១០ចឹងយើងអត់ធ្វើការទេហើយគេរាប់ដល់បាន១០ថ្ងៃចឹងគេ
ហើយគេអោយយើងឈប់ចឹងទៅណាស់។

ក៖ ចាស ហើយចឹងកាលនឹងគេមានធ្វើបាបអីអត់ចឹង?

ខ៖ ហឺយ គេធ្វើដែល ពួកខ្ញុំនៅកងកុមារតោះហាត់រត់
ដល់ពេលរត់ចឹងគេចាប់បានគេយកទៅចង់នៅដើត្រែតដែលខ្ញុំ។

ក៖ ហើយចឹង

ខ៖ ពេលចង់នឹងគ្នាច្រើន។

ក៖ ហើយគេចង់នឹងមិនមែនចង់តែអីទេន់?

ខ៖ អត់ទេបើយើងរត់នឹងមិនមែនរត់តែយើង រត់បីនាក់ចឹងដល់ពេលគេហៅចង់
គេចង់ទាំងបីនាក់នឹងនៅដើមត្រែតនឹងទៅមានអី។

ក៖ ហើយស្មាណាបានគេអោយទៅផ្ទះវិញ?

ខ៖ អានឹងដល់ល្ងាចនោះបានគេស្រាយ ហើយបានគេទុកយើងនៅចោលនឹងុ។

ក៖ ១ថ្ងៃម៉ង់?

ខ៖ ចាស១ថ្ងៃពេញ

ក៖ មានន័យថាពេលព្រឹករហូតដល់ពេលថ្ងៃ។

ខ៖ ចាស ពេលព្រឹកដល់ល្ងាចគេចេញពីធ្វើការម៉ោងប៉ុន្មានគេប្រលែងយើងម៉ោងនឹង។

ក៖ កាលនឹងមេចបានអីរត់ចឹង?

ខ៖ កាលនឹងនៅកងកុមារគេអោយយើងទៅរកអីមកវែកអាចម៍
ដល់ចឹងខ្ញុំរកអត់បានចឹងខ្ញុំនាំគ្នារត់ចូលក្នុងព្រៃ តែដល់ពេលល្ងាចឡើងមករកបាយអីហូបចឹង
គេចាប់អោយចូលវិញចឹងគេចាប់អោយកងកុមារឈប់អោយរត់។

ក៖ ហាហា តែគេអត់មានបានវៃអីទេ?

ខ៖ អត់ទេគេគ្រាន់តែចង់យើងជាប់ចោលនឹងតែចង់នឹងវាមាលនេះដែលនឹង។

កៈ ក្ដៅ?

ខៈ មាលរឹងដៃរឹងជើងដែលនឹង។

កៈ ហឺ មានន័យថាម៉េចទៅអ៊ីគេ?

ខៈ គេចង់ខ្ញុំរត់នៅកងកុមារ ចាសដល់ពេលពួកខ្ញុំអត់មានបានរត់ទៅបងប្អូនទេខ្ញុំរត់ចូលព្រៃ
រត់ចឹងហើយដល់ពេលយើងរត់ចង់ចូលកងកុមារវិញ
ទៅហើយពេលគេហៅអោយចូលយើងមិនចូលតែដល់ពេលគេឃើញយើងរត់ចឹងគេយកយើង
ទៅចង់ដើមត្រែត ហើយដាក់ដៃយើងចង់ពីក្រោយ តែដល់ពេលហើយរឹងដៃរឹងជើង
ចង់ទៅដែលហាហា។

កៈ គេចង់អ៊ីឆ្កាងគេចង់អោប?

ខៈ គេចង់ចៃគ គេចង់យើងអោយតឹងដោយរឹតនឹងក្រមា។

កៈ ចឹងយើងរួយដៃហើយ ចុះជើង?

ខៈ ចង់ស្លាក់ខ្យល់ដែល ហើយដល់ជើងស្រដូក ធម្មតានឹង។

កៈ អោយអង្គុយតើនឹង?

ខៈ ចាស

កៈ អោយអង្គុយដល់ពេលខ្ញុំស្រមៃរូបភាពនឹងទៅដូចនេះដែល
ហើយអឺយកាលនឹងអ៊ីឆ្លងកាត់បទពិសោធន៍ចឹងគេអោយរបបអាហារអីគេអោយបាយញុំាជាបា
យឬជាបបរ?

ខៈ អានឹង ខ្ញុំនៅកងកុមារគេអោយបាយ
ខ្ញុំគេអោយធ្វើស្នូតមួយសំរាប់ដាក់បាយដល់អានឹងគេចែកបាយសំរាប់ដាក់បាយ១កូនស្មុកតែប៉ុ
នឹងយើងហូបទៅ។

កៈ ហឺ បានបាយពិសា

ខៈ ចាស

កៈ ហើយម្ហូបអីម៉េចដែល?

ខៈ
ម្ហូបអីដូចជាសំឡត្នោតនឹងសំឡប្រឡិតត្រកួនអីស្រោចតែចុងភៅគេស្លអោយយើងហូបដើមចេកល្ហុងអីចឹងទៅ ត្រកួន។

កៈ ចាស ឆ្ងាញទេកាលនឹងអ៊ី?

ខៈ ហឺ កាលនឹងអត់ឆ្ងាញ់មានតែស្លាប់ហាហា ទ្រាំឆ្ងាញ់ហាហា ចាស។

កៈ ចុះឥឡូវយើងនិយាយកាលពីជំនាន់នឹងអ៊ីមានរស់ជាតិឬក៏ឆ្ងាញ់ក៏អត់?

ខៈ ដូចថាអានឹងគ្មានអីត្រូវឆ្ងាញ់ទេមានតែត្រីដូចថា ស្ល១ខ្ទះត្រីមួយដុំ។

កៈ អ៊ីស សុះតែបន្លែ

ខៈ សុះតែបន្លែ

កៈ អូចឹងពិបាកលែបដែលន៎?
ខៈ ពិបាក អានឹងបើយើងតស៊ូ អ្នកខ្លះស្លាប់ទៅចឹងហាហ៎
តែបើថាទឹកដោះម្ដាយយើងថ្លៃចឹងទៅយើងអត់ស្លាប់ទៅ។
យើងត្នោតទុំអីចឹងពេលយើងសំរាកអីចេះតែកកេរហូបទៅ។

កៈ ហូស បានទាំងញុំាត្នោតទុំដែលប៉ុនកាលនឹងញុំាកើតដែល?

ខៈ កើតដែលមានទៅអី ពេលយើងឃ្លានយើងញុំាទៅឆ្អែកដែលតើអត់មានអីអានឹងហូបទៅឆ្អែក
តើចឹងយើងចិតចំហុយក៏កើតតែយើងមិនអាចចិតចំហុយបានទេព្រោះគេមិនអោយផ្ទះមួយៗគេមិនអោយយើងមានភ្លើងចេញ
ផ្ទះហុយអីទេណាខ្លាចឆ្លបគេចាប់ពេលចឹងយើងច្រើនហូបនៅ។

កៈ ហឺ ចុះអីមានធ្លាប់លួចហូបអីក្រៅពីអី ត្នោតទុំនឹងអត់?

ខ៖ ធ្លាប់កម្រអំពិលកម្រត្នោតអីនឹង អោយគ្នាញ៉ាំ ហើយចែកគ្នា
ញ៉ាំទាំងអស់គ្នានឹងកាលនៅជំនាន់នឹង។

ក៖ កម្រត្នោតអី?

ខ៖ អាកម្រត្នោតគេយកអាខ្ចៅៗវាចេញ
ហើយថាដើមអំបិលយើងនៅកណ្តាលផ្លូវចឹងយើងស្ងួចយកមកចែកគ្នាហូបមកចែកគ្នាម្នាក់ៗ
ទៅ។

ក៖ ក្តឹមអំបិលហ៎?

ខ៖ នឹងហើយ សំបកអំបិលនឹងហូបចឹងហូបកាលនឹងឃ្លាន តែជំនាន់នឹងដូចអត់មានឈឺអីផង
អត់ដែលឈឺអីនឹងគេទេ ទោះតឡូវក៏អត់ឈឺនឹងគេទេ។

ក៖ ចឹងទៅរាងស្រួលខ្លួន

ខ៖ ចាស បើខ្ញុំឈឺផងកូនដឹងតែអត់ហើយ ព្រោះអត់មាននរណាគេចិញ្ចឹម។

ក៖ ចុះដល់ពេលចឹងអត់មានដែលឈឺដែលអីចឹងគេមានធ្លាប់សួរអ៊ីកង
ដូចថាអ្នកមើលថែអ៊ីមានបានមកសួរអ៊ីទៅណាទៅនៃឬក៏ធ្វើអោយអ៊ីពិបាកចិត្តអីទេកាលនឹង?

ខ៖ ពេលជំនាន់ពពតនឹងហោស

ក៖ ចាស

ខ៖
យើងពិបាកដែលប៉ុន្តែយើងតស៊ូយើងដឹងទៅណាទេយើងអត់ធ្មត់យើងអត់ដឹងទៅណាគេធ្វើកា
រគ្រប់គ្នាទាំងកងកុមារទាំងអស់គេប្រមូលមនុស្សទៅទាំងអស់ទាំងស្រីទាំងប្រុស។

ក៖ អ៊ីមានធ្លាប់ឃើញគេយកក្មេងៗទៅសំលាប់ចោលទេ?

ខ៖ ធ្លាប់តើ

ក៖ ផ្ទាល់ភ្នែកតែម្តង?

ខ៖ ចាស អានឹងគេយកចង់ទាំងខ្សែ។

ក៖ អឺម

ខ៖ ពេលធ្វើខុស

ក៖ ធ្វើខុសអ្វីខ្លះទៅអី?

ខ៖ ធ្វើខុសដូចថាយើងលួចដំឡូងគេ លួចអីគេនឹងគេឆ្លបទាន់ចឹងទៅណាគេឆ្លបវៃអីចឹងទៅ។

ក៖ ឆ្លបទាន់ប៉ុន្មានដង?

ខ៖ គេទាន់១ដងទៅ២ដងគេណែនាំយើងថាថ្ងៃក្រោយឈប់អោយលួចទៀតចឹង
បើយើងនៅធ្វើទៀតចឹងគេវៃយើងចោលនឹងបើយើងអត់ធ្វើអត់អីទៅ។

ក៖ ចាស ចឹងកាលនឹងអីភ័យទេ?

ខ៖ ភ័យដែលកាលនឹងដឹងគេដឹងយើងហាហា។

ក៖
ចេះតែខំតស៊ូហើយអីមានដែលនឹកគិតចង់អោយរបបនឹងដាច់ចេញអោយលឿនៗទេធ្លាប់ទេ?

ខ៖ ធ្លាប់ដែល ធ្លាប់ថាដែល តែចង់អោយបែកលឿនៗទៅព្រោះពិបាកពេក។

ក៖ ចុះអីបានធ្វើអ្វីគេខ្លះកាលនឹង?
ចឹងអីគ្រាន់តែមាននៅក្នុងចិត្តអត់បាននិយាយទៅប្រាប់គេទេ?

ខ៖ គ្រាន់តែគិតនៅក្នុងចិត្តមិនបាននិយាយជាមួយគេទេ
ខ្លាចគេយកយើងទៅវៃចោលអានឹងតវ៉ាវាអត់បានទេ។

ក៖ នឹងហើយ

ខ៖ គ្រាន់តែនឹកនៅក្នុងចិត្ត។

ក៖ កាលនឹងយើងធ្វើគធ្វើថ្លង់ចេះតែទៅជាមួយគេជាមួយង?

ខ៖ ចាស

ក៖ អ៊ីកាលនឹងបានរៀនទេកាលជំនាន់អាពត?

ខ៖ ខ្ញុំអត់បានរៀនផងទើបបានបែកហើយបានបានរៀន។

ក៖ បានរៀនថ្នាក់ទីប៉ុន្មានដែល?

ខ៖ បានរៀនត្រឹមថ្នាក់ទី៥

ក៖ ចឹង

ខ៖ នៅជាមួយមីងរហូត

ក៖ សាលាណាដែល?

ខ៖
រៀននៅសាលាព្រៃនពួតនឹងដល់ពេលអ៊ុំគាត់យកទៅភ្នំពេញនឹងបានរៀនខ្លះទៅអត់ខ្លះទៅ។

ក៖ ចុះអ៊ីចេះសរសេរចេះអាន?

ខ៖ តែឥឡូវមើលលែងឃើញហើយមើលវាមិនសូវឃើញ។

ក៖ ហើយអ៊ីនេះហ៎ អីស
ហេតុអ្វីបានជាអ៊ីឈប់រៀនត្រឹមថ្នាក់ទី៥ព្រោះនៅសល់តែមួយថ្នាក់ទៀតបានរៀនថ្នាក់ទី៦ប្រឡងចូលអនុវិទ្យាល័យហើយអនុវិទ្យាល័យចប់ទៀតរៀនបន្តទៅវិទ្យាល័យនៅទី៩ទី១០ទី១១អីចឹងទៅណាទី១២ហើយអ៊ីបានប្រឡងចប់ឌីប្លូមហើយដូចនេះតើហេតុអ្វីបានជាអ៊ីសំរេចចិត្តថាឈប់រៀននៅថ្នាក់ទី៥ថ្នាក់បឋមចឹងមិនបន្តទៅដល់អនុទៀតទៅ?

ខ៖ អត់ព្រោះអីយើងកំព្រើកំព្រាចឹងទៅនៅជាមួយអ៊ុំ
អ៊ុំចិញ្ចឹមក្មួយកំព្រាច្រើនដែលនៅជាមួយតាំងពីយើងផង គេផងដល់ចឹងគាត់អោយឈប់ខ្លះ។

ក៖ ហឺ ចឹងអ៊ីក៏សំរាចចិត្តថាឈប់ទៅ?

ខ៖ ចាស

កៈ កាលនឹងអ៊ីរៀនពូកែទេ?

ខៈ ខ្ញុំរៀនអត់សូវពូកែដែលនឹង។

កៈ បានលេខប៉ុន្មានដែលអ៊ីមាននៅចាំទេ?

ខៈ កាលនឹងបានត្រឹមលេខ១៥អីនឹងគ្មានបានច្រើនទេព្រោះយើងរៀន។

កៈ ចាសចឹងគ្រាន់បើដែលហើយអ៊ីនៅចាំទៀត
ហើយឥឡូវនៅមានសៀវភៅតាមដាននឹងនៅមើលអត់?

ខៈ អត់

កៈ បាត់អស់ហើយ យូរឆ្នាំហើយ ចាស អ៊ីមានមិត្តភក្តិអត់កាលនឹង?

ខៈ ខ្ញុំមាន

កៈ ចុះអ៊ីចូលចិត្តលេងល្បែងអីជាងគេជាមួយមិត្តភក្តិកាលនឹងកាលនៅក្មេងៗ?

ខៈ ខ្ញុំចូលចិត្តលេងអង្គុញ លេងបិទពួនលេងអីនឹង ហាហា

កៈ ហាហា សប្បាយឥឡូវនៅតែស្គាល់ពួកគាត់?

ខៈ នៅ តែពួកគាត់បែកគ្នាអស់ហើយ។

កៈ តែអ៊ីបើឃើញមុខស្គាល់តែម្តង?

ខៈ ចាស

កៈ ចាំឈ្មោះពួកគាត់អត់?

ខៈ ចាំ

កៈ ពួកគាត់ឈ្មោះអ្វីខ្លះអ៊ី?

ខៈ មិត្តភក្តិខ្ញុំ?

ក៖ ចាស

ខ៖ ឈ្មោះ ឆលីកា ហើយនឹងអាហ្វូល ឡេងតែ៣នាក់ទេហាហាហា។

ក៖ តែ៣នាក់នឹងជិតដិតជាងគេតែម្តង?

ខ៖ ចាស

ក៖ សព្វថ្ងៃមានបានទាក់ទងគ្នាទេ?

ខ៖ អត់ ខ្ញុំអត់ដែលទៅហើយគេមិនដែលមកព្រោះមិនដឹងគ្នានៅឯណា
វាធំៗរៀងខ្លួនអស់ហើយ។

ក៖ ចាស ហើយខ្ញុំសង្ឃឹមថាពេលដែលគាត់បានស្តាប់ពួកគាត់អាចរកទាក់ទងមកបាន។

ខ៖ ចាស

ក៖ ចាស ហើយអ៊ីតាំងពីកាលសិក្សារហូតមកអ៊ីធ្លាប់ជួបកាលលំបាកច្រើនត្រូវអត់អ៊ី?

ខ៖ ចាស

ក៖ ចឹងកាលលំបាករបស់អ៊ីដែលចង់ចាំជាគេបំផុតតែមួយដងនៅក្នុងជីវិតរបស់អ៊ី?

ខ៖ ចង់ចាំដែលគេធ្វើបាបមែន?

ក៖ ចាស

ខ៖ ចង់ចាំជាងគេប្តីធ្វើបាបនឹងខ្ញុំចង់ចាំមួយជីវិតចាំអត់ភ្លេចទេ
ទាល់តែស្លាប់ទៅក៏មិនភ្លេចដែល?

ក៖ គាត់បានធ្វើអ្វីខ្លះដល់អ៊ីចង់ចាំអត់ភ្លេចសោះឡើយ?

ខ៖
យកស្បែកជើងវៃខ្ញុំដល់យកស្បែកជើងវៃក្បាលខ្ញុំដល់ហើយទៅខ្ញុំឈឺចាប់ដល់ហើយខ្ញុំបំផ្លេញ
អត់បានទេ។

កៈ កាលនឹងអ៊ីធ្វើអ្វីខុស?

ខៈ ធ្វើ អត់ធ្វើអីផងនៅអង្គុយតែដល់ពេលហើយគាត់យកជើងវៃ។

កៈ ហ៊ើ សុខៗចឹងម៉ង់ គាត់ស្រវឹកអត់ដឹងខ្លួនន់អ៊ីនេហ៎?

គៈ គាត់ប្រចាន់

កៈ គាត់ប្រចាន់ហ៊ើ គាត់ខូច? ចាស់ហើយនឹង។

ខៈ ខ្ញុំចាំអត់ភ្លេចទេសុំប្បីតែកូនខ្ញុំវាក៏ឃើញ
វាឃើញទិទភាពបែបនឹងវាថាអត់ទេអត់ទទួលយកធ្វើជាឪវាបានទេ។

កៈ ហ៊ើ កូនទើបតែរៀនត្រឹមថ្នាក់ទី២ក៏វាចេះដឹងដែលចាំ
ហើយដល់ពេលចឹងអ៊ីនៅមិនទាន់លែងលះគ្នាឬក៏អ៊ីនៅតែមិនទាន់លែងទេ?

ខៈ ខ្ញុំលែង លែងដាច់តែម្តង អត់មានយកវិញទេ ទទួលយកវិញអត់បានទេ។

កៈ ចុះកូន កូនអ៊ីគាត់ប្រាប់អ៊ីថាយ៉ាងម៉េចដែល?

ខៈ ប្រាប់ថាបើម៉ែឯយកទៀតចង់បាយលាយទឹកភ្នែកមែន?

កៈ អូ គាត់និយាយចឹងផង?ហ៊ើ គាត់គិតយើងណាអ៊ីចាស។
អត់អ៊ីទេចឹងអ៊ីរាល់ថ្ងៃចិញ្ចឹមកូនមួយចឹងអ៊ីមានចង់រកអ្នកផ្សេងពីគាត់អត់?

ខៈ អត់ទេ

កៈ ហាហាហ

ខៈ ហាហាហា

កៈ អូ នឹងហើយត្រូវចង់នៅក្នុងចិត្តដូចថានៅមានស្រលាញ់នរណាផ្សេង
ដូចថាបើកបេះដូងខ្លួនឯងទទួលអ្នកផ្សេងអីអត់?ហាហា

ខៈ យកទៀតតែដល់ពេលណាដែលត្រូវទទួលនៅមើល អ្នកណាដែលត្រូវទទួល
តែមើលទៅដូចថាទាល់តែគេល្អគេមានចិត្តធម៌មកយើងបានទទួលយកខ្លាចតែគេយកទៅយើ

ងមើលដូចយើងចាប់លេខផ្សេងសំណាងចឹង ប៉ះចំអត់សំណាង
រឹតតែដូចអាមុនទៀតអាម៉េចទៅ
គេថាអោយយកអាក្រោយកុំអោយដូចអាមុនអោយគ្រាន់ជាងអាមុនបើមិនគ្រាន់ជាងអាមុនទៀតចប់។

ក៖ ចាសចឹងត្រូវមើលចិត្តគ្នាសិន

ខ៖ ចាស

ក៖ ហើយអ៊ីពេលដែលអ៊ីគ្រៀមគ្រំពិបាកចិត្តអ៊ីចូលចិត្តធ្វើអីគេ

ខ៖ ខ្ញុំចូលចិត្តធ្វើការធ្វើអីចឹងបន្លំដើម្បីកុំអោយនឹកឃើញការឈឺចាប់នឹង។

ក៖ ចុះអ៊ីចូលចិត្តស្តាប់បទចម្រៀងទេ?

ខ៖ ស្តាប់តើចូលចិត្តតើ។

ក៖ បទអីគេដែលអ៊ីចូលចិត្តស្តាប់ជាងគេ?

ខ៖ ចូលចិត្តបទអ៊ុំ ស៊ុន ស៊ីសាមុតនិង អ៊ុ រស សិរិសុធា។

ក៖ អ៊ីមានចាំបទដែលឬទេ?

ខ៖ ចាំ

ក៖ ចំណងជើងបទអីដែលអ៊ី?

ខ៖ ដូចបទអ៊ុំ រស សិរីសុធា ចូលចិត្តបទ ចិត្តអើយកុំនឹងទឹកភ្នែកអើយកុំហូរ។

ក៖ ចាសមានន័យមែន ចុះបទអ្វីទៀតទៅ?

ខ៖ ហើយបទអីគេអាទឹកភ្នែកអើយកុំហូរនឹង ហើយនឹងបទអីគេ កន្សែងក្រហមបទរបស់អ៊ុំស៊ុន ស៊ីសាមុត។

ក៖ អូ ហើយពីនឹងអ៊ីមានចាំបទអីទៀតអត់?

ខ៖ អូនមើលក្នុងសួន។

ក៖ ហើយសព្វថ្ងៃនៅតែស្តាប់ដដែល?

ខ៖ ចាស

ក៖ ហើយអ៊ីមានទូរទស្សន៍ វិទ្យុ?

ខ៖ អត់ផងខ្ញុំអត់មានផង

ក៖ អត់មានវិទ្យុទេ?

ខ៖ មានទូរសព្ទ័តែអត់ចេះបើកបទចម្រៀងស្តាប់ផង។ហាហា

ក៖ ចឹងអ៊ីបានអីស្តាប់?

ខ៖ អត់ស្តាប់តែពេលគេបើកទូរទស្សន៍អីចេះតែស្តាប់ផ្ទះគេ ហើយបើកលឺៗចឹង។

ក៖ អូ ហើយ អើយដល់ពេលយើស្តាប់ទៅចេះតែមានអារម្មណ៍ល្អជាងមុននឹងន៎អ៊ីនេហ៎?

ខ៖ ចាស

ក៖ ចុះជាតាមរយះនឹងអ៊ី អើយអ៊ីគិតថានឹងមានគំរោងអ្វីគេសំរាប់ថ្ងៃអនាគត? អត់អីទេអ៊ីដូចថាតាំងពីតូចមកដល់ធំអ៊ីធ្លាប់មានចិត្តថាចង់ក្លាយជាអ្វីដែលពេលធំឡើង?

ខ៖ កាលនៅក្មេងហាហ៎?

ក៖ ចាស

ខ៖ ខ្ញុំចង់ក្លាយជាអ្នករកស៊ីមុខជំនួនធំៗតែវាធ្វើមិនបាន ហាហា អត់ដូចបំណង។

ក៖ មុខជំនាញឬជំនួនផ្នែកអ្វីដែល?

ខ៖ ដូចជាលក់ដូរអីនឹង។

ក៖ លក់ដូរនៅផ្ទះហ៎?

ខ៖ ចាស

ក៖ លក់ឥវ៉ាន់ចាបហួយអីចឹងហ៎?

ខ៖ ចាស

ក៖ តែអានឹងយើងមានដើមយើងធ្វើបានហើយ

ខ៖ មានដើមធ្វើបានហើយ

ក៖ ចាស
ជូនពរអ៊ីអោយបានសំរេចហើយអ៊ីសន្សំលុយអីទៅអាចធ្វើការហើយលក់ដូរបន្តិចបន្តួច
ហើយអ៊ីមួយទៀតឥឡូវនឹងអ៊ីមានផែនការគំរោងអីគេដើម្បីនឹងទៅថ្ងៃអានាគតសំរាប់អោយកូន
ក៏ដូចជាខ្លួនរបស់អ៊ី?

ខ៖ ហឺ មិនដឹងថារកអីទុកអោយកូនទេ រកមិនបាន។

ក៖ សន្សំលុយ ធ្វើការងារឬធ្វើការងារអ្វីផ្សេង?

ខ៖ នឹងហើយសន្សំលុយគ្រាន់ទុកអោយកូន

ក៖ អ៊ីចង់ធ្វើការងារផ្សេងទេ?

ខ៖ ចង់ដែល

ក៖ ចង់ធ្វើអ្វីដែល?និយាយទៅអោយតែមានការងារធ្វើសិនណេស ?

ខ៖ ចាស

ក៖ ចឹងអ៊ីអាចធ្វើការហើយសន្សំលុយដើម្បីចិញ្ចឹមកូននិងគ្រួសារដើម្បីទុកបើកជំនួនអ៊ី។

ចាសចឹងអ៊ីជាចុងក្រោយអ៊ីមានពាក្យចុងក្រោយអ៊ីមានពាក្យផ្ដែផ្ដាំថាចង់និយាយអីទេអ៊ី?

ខ៖ អត់មានចង់និយាយអីទេ

ក៖
អ៊ីមានពាក្យជាចុងក្រោយសំរាប់ផ្តាប់ផ្តើដល់អ្នកជាពិសេសអ្នកដែលបានស្តាប់សំលេងអ៊ីដូចជាកូនចៅជំនាន់ក្រោយអោយគេបានដឹងណាហ៎?

ខ៖ ផ្តាំផ្ញើដល់កូនចៅជំនាន់ក្រោយកុំអោយជួបប្រទះដូចជាជំនាន់ខ្ញុំ
ដូចជាជំនាន់ពពតនឹងកុំអោយជួបប្រទះដូចចឹង។

ក៖ ចុះអ៊ីមានពាក្យអ្វីចង់និយាយទៀតទេ?

ខ៖ អត់

ក៖ចាស
អរគុណច្រើនអ៊ីសំរាប់ការចំណាយពេលវេលាអោយខ្ញុំបានសំភាសន៍ហើយជូនពរក្នុងឪកាសជិតចូលឆ្នាំថ្មីផង
សព្វថ្ងៃនឹងសូមជូនពរអោយអ៊ីមានសុខភាពល្អហើយនឹងក្រុមគ្រួសារទាំងកូនអោយគាត់រៀនពូកែនឹងប្រកបដោយកន្លងធម៌ហើយមួយទៀតសូមអោយអ៊ីមានសុខភាពល្អនឹងរកទទួលទានមានបាន
ជាពិសេសខំធ្វើការមានការងារថ្មីដើម្បីសន្សំលុយទុកបើកមុខជំនួនដោយខ្លួនឯង។ចាស
ចឹងសូមអរគុណអ៊ីសូមជំរាបលា។
ចឹងអ៊ីខ្ញុំសូមសួរជាចុងក្រោយទៀតតើអ៊ីអនុញ្ញាតអោយខ្ញុំយកសំលេងនឹងដាក់នៅក្នុងវេបសាយហើយអោយគេបានស្តាប់សំលេងអ៊ីបានអត់? អ៊ីយល់ព្រមទេ?

ខ៖ បាា អោយគេយកទៅផ្សាយទៅអត់អីទេ។

ក៖ ចាស អរគុណច្រើនអ៊ី។